សុពលភាព 2021

KNOWLEDGE TRANSFER

EAST-WEST SEED FOUNDATION



# ស្លាកសញ្ញាណែនាំ ពីថ្នាំកសិកម្ម

## ការណែនាំអំពីបច្ចេកទេស



• តើហេតុអ្វីបានជាស្លាកសញ្ញាណែនាំពីថ្នាំកសិកម្មមានសារៈសំខាន់ ?

CAMBODIA

ស្លាកសញ្ញាណែនាំពីថ្នាំកសិកម្មផ្តល់ព័ត៌មានសំខាន់ៗអំពី៖





ព័ត៌មានលំអិតពីផលិតផល



ការណែនាំអំពីរបៀបប្រើប្រាស់
ការរក្សាទុក និងការបោះចោល



ការណែនាំពីកម្រិតគ្រោះថ្នាក់




ការលាយផ្សំធាតុសកម្ម (ឧទាហរណ៍៖ ៧៥%) និងទម្រង់បង្កើត (ឧទាហរណ៍៖ ជាម្សៅដែលអាចសើម ឬ WP)

កូដពណ៌ (បៃតង ខៀវ លឿង និងក្រហម) និងរូបសញ្ញាណែនាំ
មើលនៅក្នុង សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្ម សម្រាប់ព័ត៌មានបន្ថែម

## ការណែនាំពីការប្រើប្រាស់

- ដំណាំ សត្វល្អិតចង្រៃ កម្រិតប្រើ ការលាយ និងការពង្រាវនៃផលិតផល ពេលវេលាត្រូវប្រើ ភាពមិនត្រូវគ្នា វិធីប្រើប្រាស់ ។ ល។

## ចំណាំ: ជាទូទៅត្រូវធ្វើតាមការណែនាំ!

## ពេលវេលាអាចចូលចម្ការបានវិញ

- ពេលវេលាដែលអ្នកត្រូវបានគេអនុញ្ញាតឱ្យចូលបន្ទាប់ពីការបាញ់ថ្នាំ
- ឧទាហរណ៍៖ ១២ម៉ោងបន្ទាប់ពីបាញ់ថ្នាំកសិកម្ម

## ពេលវេលាចន្លោះមុនពេលប្រមូលផល

- ពេលវេលាត្រូវរង់ចាំរវាងរយៈពេលបាញ់ថ្នាំ និងពេលដែលដំណាំត្រូវប្រមូលផល
- ឧទាហរណ៍៖ ១៤ថ្ងៃ គ្រប់ដំណាំទាំងអស់

## សង្គ្រោះបឋម និងដំបូន្មានវេជ្ជសាស្ត្រ

- តើអ្នកគួរធ្វើអ្វីខ្លះនៅពេលដែលវាជ្រាបចូលទៅក្នុងមាត់ ស្បែក ឬ ភ្នែក ?

## ការរក្សាទុក និងការបោះចោល

- តើកន្លែងណាត្រូវរក្សាទុក ?
- តើធ្វើដូចម្តេចដើម្បីទុកដាក់បានត្រឹមត្រូវនូវសំណល់ និងសម្បកថ្នាំកសិកម្ម ?




- មើលការណែនាំពីបច្ចេកទេស បែបផែននៃធាតុសកម្ម សម្រាប់ពត៌មានបន្ថែម
- ក្រុមបែបផែននៃធាតុសកម្ម MoA
- ពត៌មានបន្ថែមថ្មីនៅក្នុងប្រទេសមួយចំនួន។

## • ហេតុអ្វីការអានស្លាកសញ្ញាណែនាំថ្នាំកសិកម្មមានសារៈសំខាន់?



ការពារខ្លួនរបស់អ្នក



ដើម្បីមានប្រសិទ្ធិភាព
អតិបរមាលើការកំចាត់
សត្វល្អិតចង្រៃ និងជំងឺ



ជៀសវាង ឬមានគ្រោះ
ថ្នាក់ជាអប្បបរមាលើសុខភាព
និងបរិស្ថាន



សន្សំសំចៃថវិកា
និងផលប្រយោជន៍
ជាអតិបរមា

## • តើពេលណាត្រូវអានស្លាកសញ្ញាណែនាំថ្នាំកសិកម្ម?

### ជាទូទៅត្រូវអានស្លាកសញ្ញាណែនាំថ្នាំកសិកម្មនៅពេលៈ





ពេលទិញ



ពេលរក្សាទុក



ពេលត្រូវបោះចោល



ពេលលាយថ្នាំកសិកម្ម



ពេលប្រើថ្នាំកសិកម្ម

| ប្រភេទ | សាររូបភាពណែនាំសុវត្ថិភាព |
|---|---|
| ការរក្សាទុក |  រក្សាទុកដោយចាក់សោរ និងទុកអោយផុតពីដៃក្មេង |
| សកម្មភាព |  ពេលលាយថ្នាំកសិកម្មដែលមានសមាសភាគរាវ <br>  ពេលលាយថ្នាំកសិកម្មដែលមានសមាសភាគស្ងួត <br>  ពេលត្រូវបាញ់ថ្នាំកសិកម្ម |
| ការផ្តល់ដំបូន្មាន |  ត្រូវពាក់ស្រោមដៃ <br>  ត្រូវពាក់បាំងការពារភ្នែក <br>  ត្រូវពាក់ស្បែកជើងកវែង <br>  ត្រូវពាក់ម៉ាស់ការពារច្រមុះ និងមាត់ <br>  ត្រូវពាក់ប្រដាប់ការពារដំណកដង្ហើម <br>  ត្រូវពាក់សម្លៀកបំពាក់ការពារខ្លួន <br>  ត្រូវពាក់អៀមការពារខោអាវ <br>  ត្រូវលាងសម្អាតដៃ បន្ទាប់ពីប្រើថ្នាំកសិកម្មរួច |
| ការប្រកាសអាសន្ន |  គ្រោះថ្នាក់ចំពោះសត្វពាហនៈ <br>  គ្រោះថ្នាក់ចំពោះត្រី - កុំបោះចូលទៅក្នុងបឹង ទន្លេ ស្រះ ឬប្រឡាយទឹក |

**http://growhow.eastwestseed.com**

*This technical guide is part of a series produced by EWSF. @2021 Copyright of East-West Seed Foundation. All Rights Reserved*

*Agrochemical recommendations have been developed in cooperation with Wageningen University & Research*

WAGENINGEN UNIVERSITY & RESEARCH